## អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា




# របាយការណ៍ប្រចាំឆមាសទី១ ឆ្នាំ២០២៤

# របាយការណ៍ប្រចាំឆមាសទី១ ឆ្នាំ២០២៤

# មាតិកា


**អារម្ភកថា** ........................................ i

**ខ្លឹមសារសង្ខេប** ........................................ iii

**ជំពូកទី១ ការងារវាយតម្លៃហានិភ័យថ្នាក់ជាតិ ស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម លើកទី២** ........................................ ១

**ជំពូកទី២ ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម** ........................................ ៣

២.១. ក្រុមប្រឹក្សាភិបាល នៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ........................................ ៣

២.២. ការងារវិភាគប្រតិបត្តិការ ........................................ ៤

២.៣. ការងារត្រួតពិនិត្យបុគ្គលរាយការណ៍ ........................................ ៥

២.៤. ការងារសហប្រតិបត្តិការ ........................................ ៥

២.៥. ការងារពង្រឹងសមត្ថភាពធនធានមនុស្ស ........................................ ១០

**ជំពូកទី៣ ទិសដៅការងារឆមាសទី២ ឆ្នាំ២០២៤** ........................................ ១៣

*អក្សរកាត់* ........................................ ១៤

# អារម្ភកថា

ក្នុងបរិបទនៃការប្រែប្រួលនិន្នាការនៃការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងការវិវត្តនៃប្រព័ន្ធបច្ចេកវិទ្យា ប្រទេសនីមួយៗបានយកចិត្តទុកដាក់ និងបានកំណត់ការងារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មជាការងារអាទិភាព និងត្រូវធានានូវនិរន្តរភាពក្នុងការអនុវត្តស្របតាមស្តង់ដាអន្តរជាតិរបស់ក្រុមការងារហិរញ្ញវត្ថុ។ បច្ចុប្បន្ន ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មតាមបណ្តាប្រទេសនានាក្នុងសកលលោក កាន់តែមានភាពស្មុគស្មាញប្រទាក់ក្រឡាគ្នា និងវិវត្តន៍ឥតឈប់ឈរ ដែលភាគីពាក់ព័ន្ធមានដូចជាក្រសួង-ស្ថាប័នសាធារណៈ វិស័យឯកជន និងភាគីបរទេស ត្រូវរួមសហការគ្នាដើម្បីឆ្លើយតបទៅនឹងនិន្នាការប្រែប្រួលនៃការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មនេះ។

ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ប្រកបដោយគតិបណ្ឌិត និងទស្សនៈវិស័យវែងឆ្ងាយរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ខ្ពស់ ក្នុងការពង្រឹងក្របខណ្ឌគតិយុត្តនិងស្ថាប័ន និងការអនុវត្តច្បាប់និងបទប្បញ្ញត្តិ ព្រមទាំងការជំរុញកិច្ចសហប្រតិបត្តិការទាំងក្នុងប្រទេសនិងអន្តរជាតិ ដើម្បីធានាបាននូវប្រសិទ្ធភាព ប្រសិទ្ធផល និងនិរន្តរភាពការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

ក្នុងស្មារតីនេះ ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលមានក្រុមប្រឹក្សាភិបាល នៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បាននិងកំពុងបំពេញតួនាទីរបស់ខ្លួនយ៉ាងសកម្ម ក្នុងការចូលរួមចំណែកអនុវត្តការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មប្រកបដោយការទទួលខុសត្រូវខ្ពស់។ ជាមួយគ្នានេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានយកចិត្តទុកដាក់ជាប្រចាំលើការវិភាគប្រតិបត្តិការ ការត្រួតពិនិត្យបុគ្គលរាយការណ៍ កិច្ចសហប្រតិបត្តិការ និងការបណ្តុះបណ្តាលនិងផ្សព្វផ្សាយ ព្រមទាំងបាននិងកំពុងសម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធលើការរៀបចំការងារវាយតម្លៃហានិភ័យថ្នាក់ជាតិលើកទី ២ ផងដែរ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះ ប្រមុខថ្នាក់ដឹកនាំរាជរដ្ឋាភិបាលកម្ពុជា គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ និងក្រុមប្រឹក្សាភិបាលនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាដែលបានផ្តល់ការគាំទ្រ និងការណែនាំរហូតសម្រេចបានសមិទ្ធផលការងារនាពេលនេះ។

ទន្ទឹមនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះ **លោកជំទាវ អគ្គទេសាភិបាល** ធនាគារជាតិនៃកម្ពុជា ដែលតែងតែយកចិត្តទុកដាក់ និងផ្តល់ការគាំទ្រយ៉ាងពេញទំហឹងដល់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រេចបានលទ្ធផលការងារដ៏គួរជាទីមោទនៈ។

ខ្ញុំសូមកោតសរសើរដល់ថ្នាក់ដឹកនាំ និងមន្ត្រី-បុគ្គលិក អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ចំពោះកិច្ចខិតខំប្រឹងប្រែងអនុវត្តការងារអស់ពីកម្លាំងកាយចិត្ត ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងមោះមុតដើម្បីសម្រេចបានលទ្ធផលជាច្រើននាពេលកន្លងមក។

ជាទីបញ្ចប់ ខ្ញុំសូមលើកទឹកចិត្តដល់ថ្នាក់ដឹកនាំ និងមន្ត្រី-បុគ្គលិក អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បន្តកិច្ចខិតខំប្រឹងប្រែងអនុវត្តលើមុខងារ-ភារកិច្ចរបស់ខ្លួន និងបន្តនិរន្តរភាពការងារឱ្យបានលទ្ធផលល្អប្រសើរ ដើម្បីធានានូវសុចរិតភាពនៃប្រព័ន្ធហិរញ្ញវត្ថុ និងបង្កើននូវជំនឿទុកចិត្តពីសាធារណជន ជាពិសេស វិនិយោគិនជាតិនិងអន្តរជាតិ។

ប្រធានក្រុមប្រឹក្សាភិបាល
អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

**សាយ សំអាត**

# ខ្លឹមសារសង្ខេប

ការវាយតម្លៃហានិភ័យថ្នាក់ជាតិ ស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម លើកទី២ បាននិងកំពុងបន្តដំណើរការ ក្រោមជំនួយបច្ចេកទេសរបស់ធនាគារពិភពលោក ដោយបានបញ្ចប់ដំណាក់កាលទី១ និងដំណាក់កាលទី២ ។ សម្រាប់ដំណាក់កាលបន្ទាប់ គឺការបូកសរុបរបាយការណ៍ និងការរៀបចំរបាយការណ៍សង្ខេប ព្រមទាំងការអនុម័តរបាយការណ៍ និងការផ្សព្វផ្សាយជាសាធារណៈ។

ក្នុងឆមាសទី១ ឆ្នាំ២០២៤ ក្រុមប្រឹក្សាភិបាលនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានបើកកិច្ចប្រជុំចំនួន ២ លើក ដើម្បីពិនិត្យវឌ្ឍនភាពការងារវាយតម្លៃហានិភ័យថ្នាក់ជាតិ និងពិភាក្សាអំពីលទ្ធផលការងាររបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។ ទន្ទឹមនេះ ក្រុមប្រឹក្សាភិបាលបានផ្តល់ការណែនាំដល់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ក្នុងការបន្តពង្រឹងការអនុវត្តការងារ និងអភិវឌ្ឍសមត្ថភាព។

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានបន្តយកចិត្តទុកដាក់ ក្នុងការវិភាគរបាយការណ៍ប្រតិបត្តិការសាច់ប្រាក់ និងរបាយការណ៍ប្រតិបត្តិការសង្ស័យ ដែលទទួលបានពីបុគ្គលរាយការណ៍ ដើម្បីបញ្ជូនរបាយការណ៍ស៊ើបការណ៍ហិរញ្ញវត្ថុដោយឯកឯង និងតាមការស្នើសុំទៅអាជ្ញាធរអនុវត្តច្បាប់ពាក់ព័ន្ធ។ ក្នុងឆមាសទី១ ឆ្នាំ២០២៤ ចំនួនរបាយការណ៍ទាំង ២ នេះ មានការថយចុះបើធៀបនឹងគ្រាដូចគ្នាឆ្នាំមុន។ ទន្ទឹមនេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានភ្ជាប់ប្រព័ន្ធរាយការណ៍ ជូនបុគ្គលរាយការណ៍ចំនួន ៥២ មកពីក្រុមហ៊ុនជានាវ៉ាប់រង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ កាស៊ីណូ ក្រុមហ៊ុនអចលនវត្ថុ និងក្រុមហ៊ុនមូលបត្រ។

ចំពោះការត្រួតពិនិត្យ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានបន្តអនុវត្តត្រួតពិនិត្យដល់ទីកន្លែង និងត្រួតពិនិត្យលើឯកសារ ដោយយកចិត្តទុកដាក់ តាមផែនការដែលបានគ្រោងទុក។ ក្នុងន័យនេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានចុះត្រួតពិនិត្យដល់ទីកន្លែង ចំពោះបុគ្គលរាយការណ៍ចំនួន ១៩ ព្រមទាំងបានចេញលិខិតព្រមានចំពោះបុគ្គលរាយការណ៍ដែលពុំបានអនុវត្តពេញលេញតាមច្បាប់និងបទប្បញ្ញត្តិ។ បន្ថែមពីនេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានទទួលស្គាល់មន្ត្រីប្រតិបត្តិចំនួន ៤៧ រូប មកពីធនាគារពាណិជ្ជ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ កាស៊ីណូ ក្រុមហ៊ុនអចលនវត្ថុ ក្រុមហ៊ុនជានាវ៉ាប់រង ក្រុមហ៊ុនមូលបត្រ ជាដើម។

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានបន្តយកចិត្តទុកដាក់លើការងារសហប្រតិបត្តិការទាំងក្នុង និងក្រៅប្រទេស។ ក្នុងន័យនេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានកែសម្រួល និង

ចុះអនុស្សរណៈយោគយល់សារជាថ្មីជាមួយអគ្គនាយកដ្ឋានពន្ធដារ។ ក្រៅពីនេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានចូលរួមកិច្ចប្រជុំ និងមហាសន្និបាតជាមួយដៃគូអន្តរជាតិ ដូចជាក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ (Asia/Pacific Group on Money Laundering - APG) ក្រុមអ៊ិកម៉ុង (The Egmont Group) និងក្រុមការងារប្រឹក្សាយោបល់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ (Financial Intelligence Consultative Group - FICG) ជាដើម។

ដើម្បីធានាបាននូវនិរន្តរភាពការងារ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានបន្តយកចិត្តទុកដាក់លើការបណ្តុះបណ្តាលធនធានមនុស្សជាប្រចាំ។ ជាក់ស្តែង ក្នុងឆមាសទី១ នេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានរៀបចំវគ្គបណ្តុះបណ្តាលផ្ទៃក្នុងចំនួន ២ លើក ជូនមន្ត្រី-បុគ្គលិកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ចំនួន ៤៨ រូប និងចំនួន ១ លើក ជូនមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា ចំនួន ៤០ រូប។ ក្រៅពីនេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយជូនបុគ្គលរាយការណ៍ និងមជ្ឈដ្ឋានសិក្សា ចំនួន ៩ លើក ព្រមទាំងបានចូលរួមជាវាគ្មិនចំនួន ១២ លើក។ ជាមួយគ្នាផងដែរ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានចាត់បញ្ជូនមន្ត្រី-បុគ្គលិកចូលរួមសិក្ខាសាលាក្នុង និងក្រៅប្រទេស ដែលរៀបចំដោយក្រសួង-ស្ថាប័នជាតិ និងអន្តរជាតិ សរុបចំនួន ១៥ លើក។

# ជំពូកទី១
# ការវាយតម្លៃហានិភ័យថ្នាក់ជាតិ ស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម លើកទី២

ប្រទេសកម្ពុជាបន្តទទួលបានជំនួយបច្ចេកទេសពីធនាគារពិភពលោក ក្នុងការរៀបចំដំណើរការវាយតម្លៃហានិភ័យថ្នាក់ជាតិ ស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម លើកទី២ ដែលវិធីសាស្ត្រវាយតម្លៃលើកនេះ គឺមានចំនួន ១៤ ម៉ូឌុល ច្រើនជាងវិធីសាស្ត្រវាយតម្លៃកាលពីលើកទី១ ដែលមានតែចំនួន ៩ ម៉ូឌុល ប៉ុណ្ណោះ។ ការពង្រីកវិសាលភាពនៃវិធីសាស្ត្រវាយតម្លៃនេះ នឹងរួមចំណែកដល់ការកំណត់ហានិភ័យថ្នាក់ជាតិរបស់ប្រទេសកម្ពុជាឱ្យកាន់តែគ្រប់ជ្រុងជ្រោយ និងស្របតាមស្តង់ដាអន្តរជាតិរបស់ក្រុមការងារហិរញ្ញវត្ថុ (Financial Action Task Force-FATF)។

ការរៀបចំការវាយតម្លៃហានិភ័យថ្នាក់ជាតិ ស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម លើកទី២ ត្រូវបានបែងចែកជា ៤ ដំណាក់កាល ដូចខាងក្រោម៖

១/- **ដំណាក់កាលទី ១៖** ការបណ្តុះបណ្តាលអំពីឧបករណ៍វាយតម្លៃរបស់ម៉ូឌុលនីមួយៗ

២/- **ដំណាក់កាលទី ២៖** ការប្រមូល និងវិភាគទិន្នន័យ ដើម្បីរៀបចំរបាយការណ៍ហានិភ័យទៅតាមម៉ូឌុលនីមួយៗ

៣/- **ដំណាក់កាលទី ៣៖** ការបូកសរុបរបាយការណ៍វាយតម្លៃហានិភ័យថ្នាក់ជាតិ និងរៀបចំរបាយការណ៍សង្ខេប និង

៤/- **ដំណាក់កាលទី ៤៖** ការអនុម័តរបាយការណ៍វាយតម្លៃហានិភ័យថ្នាក់ជាតិ និងរបាយការណ៍សង្ខេបដោយគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ ស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (គ.ស.ហ.) និងផ្សព្វផ្សាយជាសាធារណៈនូវរបាយការណ៍សង្ខេប។



**កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (គ.ស.ហ.)**
**នាថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៤ នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា**

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានរាយការណ៍វឌ្ឍនភាពការងារនៃការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម លើកទី២ ជូនគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (គ.ស.ហ.) នាកិច្ចប្រជុំដែលបានប្រព្រឹត្តទៅនៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៤។

ក្នុងឆមាសទី១ ឆ្នាំ២០២៤ ការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម លើកទី២ បានបញ្ចប់ដំណាក់កាលទី១ និងទី២ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

**១/- ដំណាក់កាលទី១ ៖** អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានសហការជាមួយជំនាញការធនាគារពិភពលោក រៀបចំការបណ្តុះបណ្តាលលើឧបករណ៍វាយតម្លៃហានិភ័យសម្រាប់ម៉ូឌុលទាំង ១៤ និងរៀបចំសិក្ខាសាលាពិគ្រោះយោបល់ (Consultative Workshop) អំពីការវាយតម្លៃហានិភ័យថ្នាក់ជាតិ ស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម លើកទី២ ដោយមានសិក្ខាកាមចូលរួមសរុបចំនួន ៣៦៤ រូប មកពីក្រសួង-ស្ថាប័នពាក់ព័ន្ធចំនួន ១៩ ។ សិក្ខាសាលានេះបានផ្តល់ឱកាសដល់សិក្ខាកាមពិនិត្យ និងពិភាក្សាអំពីលទ្ធផលបឋមរបស់ម៉ូឌុលទាំង ១៤ ព្រមទាំងបានផ្តល់ដំណោះស្រាយលើបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងការប្រមូលទិន្នន័យ ការវិភាគលទ្ធផល ការផ្តល់ចំណាត់ថ្នាក់ និងការប្រើប្រាស់ឧបករណ៍វាយតម្លៃហានិភ័យរបស់ធនាគារពិភពលោក ផងដែរ។




**សិក្ខាសាលាពិគ្រោះយោបល់ជាមួយធនាគារពិភពលោក អំពីការវាយតម្លៃហានិភ័យថ្នាក់ជាតិ ស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម លើកទី២ ចាប់ពីថ្ងៃទី២២-២៦ ខែមករា ឆ្នាំ២០២៤ នៅធនាគារជាតិនៃកម្ពុជា អគារសែនសុខ**

**២/- ដំណាក់កាលទី២៖** ក្រុមការងារទទួលបន្ទុកតាមម៉ូឌុលនីមួយៗបានបញ្ចប់ការប្រមូលនិងវិភាគទិន្នន័យ និងរៀបចំរបាយការណ៍វាយតម្លៃតាមវិស័យរបស់ខ្លួន ព្រមទាំងបានបញ្ជូនមកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដើម្បីសរុបលទ្ធផលបឋម។

# ជំពូកទី២

# ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

## ២.១. ក្រុមប្រឹក្សាភិបាល នៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

*ក្រុមប្រឹក្សាភិបាល នៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានបើកកិច្ចប្រជុំចំនួន ២ លើក។ ក្នុងនោះកិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី៥៦ បានពិភាក្សាលើរបាយការណ៍ប្រចាំឆ្នាំ២០២៣ របស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ហើយកិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី៥៧ បានពិនិត្យលើវឌ្ឍនភាពការងារវាយតម្លៃហានិភ័យថ្នាក់ជាតិ ស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម លើកទី២ និងពិភាក្សាអំពីលទ្ធផលការងាររបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។ ទន្ទឹមគ្នានេះ ក្រុមប្រឹក្សាភិបាលបានណែនាំដល់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាក្នុងការបន្តពង្រឹងការអនុវត្តការងារប្រកបដោយការទទួលខុសត្រូវ និងមានប្រសិទ្ធភាព ព្រមទាំងយកចិត្តទុកដាក់អភិវឌ្ឍសមត្ថភាព និងជំនាញជាប្រចាំ។*




**កិច្ចប្រជុំក្រុមប្រឹក្សាភិបាល នៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា លើកទី៥៦**
**នាថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤ នៅអគារអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**




**កិច្ចប្រជុំក្រុមប្រឹក្សាភិបាល នៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា លើកទី៥៧**
**នាថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៤ នៅអគារអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**

## ២.២. ការវិភាគប្រតិបត្តិការ

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានបន្តយកចិត្តទុកដាក់ ក្នុងការបំពេញការងារវិភាគប្រតិបត្តិការ ដែលជាការងារស្នូលតាមរយៈការទទួលរបាយការណ៍ប្រតិបត្តិការសាច់ប្រាក់ (Cash Transaction Report – CTR) និងរបាយការណ៍ប្រតិបត្តិការសង្ស័យ (Suspicious Transaction Report - STR) ពីបុគ្គលរាយការណ៍ ។ ទន្ទឹមនេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាក៏បានបញ្ជូនរបាយការណ៍ស៊ើបការណ៍ហិរញ្ញវត្ថុដោយឯកឯង និងតាមការស្នើសុំទៅអាជ្ញាធរអនុវត្តច្បាប់ពាក់ព័ន្ធ ដើម្បីស៊ើបអង្កេតបទល្មើសហិរញ្ញវត្ថុស្របគ្នាជាមួយសំអាងបទល្មើស។

នៅក្នុងឆមាសទី១ ឆ្នាំ២០២៤ របាយការណ៍ប្រតិបត្តិការសាច់ប្រាក់ពីបុគ្គលរាយការណ៍មានការថយចុះ ៩,៤៨% និងរបាយការណ៍ប្រតិបត្តិការសង្ស័យមានការថយចុះ ៩,៧៣% បើធៀបនឹងឆមាសទី១ ឆ្នាំមុន។




បន្ថែមលើនេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានណែនាំ និងភ្ជាប់ប្រព័ន្ធរាយការណ៍ដល់បុគ្គលរាយការណ៍ថ្មីៗសរុបចំនួន ៥២ រួមមាន៖ ក្រុមហ៊ុនធានារ៉ាប់រង ៨ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៨ កាស៊ីណូ ២៣ ក្រុមហ៊ុនអចលនវត្ថុ ៧ និងក្រុមហ៊ុនមូលបត្រ ៦ ដើម្បីអនុវត្តការរាយការណ៍ប្រតិបត្តិការសាច់ប្រាក់ និងប្រតិបត្តិការសង្ស័យឱ្យបានត្រឹមត្រូវនិងទាន់ពេលវេលាប្រកបដោយគុណភាព។ ជាមួយគ្នានេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបាននិងកំពុងសហការជាមួយនាយកដ្ឋានព័ត៌មានវិទ្យានៃធនាគារជាតិនៃកម្ពុជាក្នុងការរៀបចំប្រព័ន្ធវិភាគការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

## ២.៣. ការងារត្រួតពិនិត្យបុគ្គលរាយការណ៍

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បន្តពង្រឹងការត្រួតពិនិត្យលើបុគ្គលរាយការណ៍អំពីការអនុលោមតាមច្បាប់និងបទប្បញ្ញត្តិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម តាមរយៈការប្រើប្រាស់វិធីសាស្ត្រត្រួតពិនិត្យផ្អែកលើហានិភ័យ។ នៅក្នុងឆមាសទី១ ឆ្នាំ២០២៤ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានត្រួតពិនិត្យដល់ទីកន្លែងចំពោះបុគ្គលរាយការណ៍សរុបចំនួន ១៩ រួមមានៈ ធនាគារពាណិជ្ជ ៤ ធនាគារឯកទេស ១ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ១ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ២ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ១ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ១ ក្រុមហ៊ុនមូលបត្រ ១ ក្រុមហ៊ុនសេវាកម្មវាយតម្លៃអចលនវត្ថុ ១ ក្រុមហ៊ុនអភិវឌ្ឍអចលនវត្ថុ ២ ក្រុមហ៊ុនភ្នាក់ងារអចលនវត្ថុ ១ និងកាស៊ីណូ ៤ ព្រមទាំងបានផ្តល់អនុសាសន៍កែតម្រូវចំពោះចំណុចខ្វះខាតផងដែរ។

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានអនុវត្តការត្រួតពិនិត្យលើឯកសារជាប្រចាំ តាមរយៈការតាមដានលទ្ធផលនៃការវាយតម្លៃហានិភ័យសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម វឌ្ឍនភាពនៃការអនុវត្តតាមអនុសាសន៍ត្រួតពិនិត្យដល់ទីកន្លែង និងលទ្ធផលនៃការត្រួតពិនិត្យផ្ទៃក្នុង និងសវនកម្មផ្ទៃក្នុងជាដើម។ ជាមួយគ្នានេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានយកចិត្តទុកដាក់លើការវាយតម្លៃគុណវុឌ្ឍិរបស់មន្ត្រីប្រតិបត្តិ ដោយបានទទួលស្គាល់មន្ត្រីប្រតិបត្តិចំនួន ៤៧ រូប មកពីធនាគារពាណិជ្ជ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រង ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនអចលនវត្ថុ កាស៊ីណូ ក្រុមហ៊ុនសវនកម្ម និងក្រុមហ៊ុនបរធនបាលកិច្ច។

ក្រៅពីនេះ ក្នុងការពង្រឹងការអនុវត្តច្បាប់និងបទប្បញ្ញត្តិរបស់បុគ្គលរាយការណ៍ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានចេញលិខិតព្រមានចំនួន ៧០ ចំពោះបុគ្គលរាយការណ៍ដែលខកខានក្នុងការអនុវត្តឱ្យបានពេញលេញ ស្របតាមការតម្រូវនៃច្បាប់និងបទប្បញ្ញត្តិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

## ២.៤. ការងារសហប្រតិបត្តិការ

### ២.៤.១ កិច្ចសហប្រតិបត្តិការក្នុងស្រុក

ក្នុងឆមាសទី១ ឆ្នាំ២០២៤ ចំពោះកិច្ចសហប្រតិបត្តិការក្នុងស្រុក អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានកែសម្រួល និងចុះអនុស្សរណៈយោគយល់សារជាថ្មីជាមួយអគ្គនាយកដ្ឋានពន្ធដារ ស្តីពីការផ្លាស់ប្តូរព័ត៌មានសម្រាប់គោលបំណងពន្ធ។ ជារួម អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

បានចុះអនុស្សរណៈយោគយល់ជាមួយក្រសួង-ស្ថាប័នក្នុងប្រទេសសរុបចំនួន ២១ និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបរទេសសរុបចំនួន ៣៦ ។

ជាមួយគ្នានេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានជួបប្រជុំជាមួយនិយ័តករបរធនបាលកិច្ចក្នុងគោលបំណងពិភាក្សាលើយន្តការត្រួតពិនិត្យលើបុគ្គលរាយការណ៍ ការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់និងបទប្បញ្ញត្តិ ពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ការផ្លាស់ប្តូរព័ត៌មាន កិច្ចសហប្រតិបត្តិការ និងការចុះអនុស្សរណៈយោគយល់រវាងស្ថាប័នទាំងពីរ។



**កិច្ចពិភាក្សារវាងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ជាមួយនិយ័តករបរធនបាលកិច្ច នាថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤ នៅធនាគារជាតិនៃកម្ពុជា អគារសែនសុខ**

## ២.៤.២ កិច្ចសហប្រតិបត្តិការអន្តរជាតិ

### ក. ក្រុមការងារហិរញ្ញវត្ថុ និងក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានបន្តសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ រៀបចំរបាយការណ៍វឌ្ឍនភាព លើកទី៦ ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម របស់ប្រទេសកម្ពុជាជូនលេខាធិការដ្ឋាននៃ APG ពាក់ព័ន្ធនឹងការអនុវត្តអនុសាសន៍របស់ក្រុមការងារហិរញ្ញវត្ថុ។

ជាមួយគ្នានេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានចូលរួមកិច្ចប្រជុំជាមួយលេខាធិការដ្ឋាននៃ APG និងក្រុមការងារហិរញ្ញវត្ថុ ដូចជា ៖ ១/- កិច្ចប្រជុំគណៈកម្មការវាយតម្លៃអញ្ញមញ្ញ ២/- កិច្ចប្រជុំគណៈកម្មការអភិបាលកិច្ច ៣/- កិច្ចប្រជុំគណៈកម្មការប្រតិបត្តិ និង ៤/- កិច្ចប្រជុំក្រុមការងារទំនាក់ទំនងផ្នែកទ្រព្យសកម្មនិម្មិត និងអ្នកផ្តល់សេវាទ្រព្យសកម្មនិម្មិត ព្រមទាំងចូលរួមវគ្គបណ្តុះបណ្តាលសម្រាប់អ្នកវាយតម្លៃ ដើម្បីទទួលបានបទពិសោធ និងឧត្តមានុវត្តន៍ល្អៗ។ ក្រៅពីនេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានផ្តល់ធាតុចូលពាក់ព័ន្ធនឹង ១/- សេចក្តីព្រាងនីតិវិធីស្តីពី

ការវាយតម្លៃអញ្ញមញ្ញជុំទី៤ របស់ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ ២/- ការស្នងមតិរបស់ក្រុមការងារហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងអនុសាសន៍ទី១៥ ស្តីពីបច្ចេកវិទ្យាថ្មីៗ ៣/- កម្រងសំណួររបស់ក្រុមការងារហិរញ្ញវត្ថុ ស្តីពីការវាយតម្លៃហានិភ័យថ្នាក់ជាតិ និង ៤/- ការអនុវត្តវិធានការចំពោះប្រទេសមានហានិភ័យខ្ពស់ដែលតម្រូវឱ្យមានវិធានការប្រឆាំង និងប្រទេសដែលត្រូវបង្កើនការតាមដាន។



**កិច្ចប្រជុំគណៈកម្មការវាយតម្លៃអញ្ញមញ្ញ របស់ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក ស្តីពីការសម្អាតប្រាក់ នាថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៤ តាមប្រព័ន្ធអនឡាញ**

### ខ. ក្រុមអ៊ិកម៉ុង

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានចូលរួមកិច្ចប្រជុំក្រុមការងាររបស់ក្រុមអ៊ិកម៉ុង និងក្រុមការងារប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិករបស់ក្រុមអ៊ិកម៉ុង នៅទីក្រុង St. Julian’s ប្រទេសម៉ាល់ត៍ ក្នុងគោលបំណងពិភាក្សាអំពីវឌ្ឍនភាពការងាររបស់ ១/- ក្រុមការងារផ្លាស់ប្តូរព័ត៌មាន ២/- ក្រុមការងារជំនួយបច្ចេកទេសនិងបណ្តុះបណ្តាល ៣/- ក្រុមការងារសមាជិកភាព ការគាំទ្រ និងអនុលោមភាព ៤/- ក្រុមការងារគោលនយោបាយនិងនីតិវិធី និង ៥/- ក្រុមការងារប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក។




**កិច្ចប្រជុំក្រុមការងារ និងក្រុមការងារប្រចាំតំបន់ ប្រចាំឆ្នាំ២០២៤ របស់ក្រុមអ៊ិកម៉ុង ចាប់ពីថ្ងៃទី២៩ ខែមករា ដល់ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៤ នៅទីក្រុង St. Julian's ប្រទេសម៉ាល់ត៍**

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានចូលរួមមហាសន្និបាតប្រចាំឆ្នាំលើកទី៣០ របស់ក្រុមអ៊ិកម៉ុង ចាប់ពីថ្ងៃទី២-៧ ខែមិថុនា ឆ្នាំ២០២៤ នៅទីក្រុងប៉ារីស ប្រទេសបារាំង ក្រោមប្រធានបទ "អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុជំនាន់ថ្មី (New Generation of FIU)"។ មហាសន្និបាតនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងចែករំលែកបទពិសោធ និងចំណេះដឹងថ្មីៗដល់សមាជិកក្នុងការអភិវឌ្ឍស្ថាប័នខ្លួនឱ្យទាន់ការវិវត្តយ៉ាងឆាប់រហ័សនៃនិន្នាការពិភពលោក ជាពិសេសវិធីសាស្ត្រថ្មីៗ ក្នុងការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ តាមរយៈការទាញយកផលប្រយោជន៍ពីការប្រើប្រាស់បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត និងការបន្តពង្រឹងនិងរក្សាធនធានមនុស្សសម្រាប់បំពេញការងារស្នូល ព្រមទាំងកិច្ចសហប្រតិបត្តិការលើការងារផ្លាស់ប្តូរព័ត៌មានប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។







**មហាសន្និបាតប្រចាំឆ្នាំលើកទី៣០ របស់ក្រុមអ៊ិកម៉ុង**
**ចាប់ពីថ្ងៃទី២-៧ ខែមិថុនា ឆ្នាំ២០២៤ នៅទីក្រុងប៉ារីស ប្រទេសបារាំង**

### គ. ក្រុមប្រឹក្សាយោបល់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាយោបល់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ ដើម្បីពិភាក្សា និងចែករំលែកវឌ្ឍនភាពការងាររបស់ប្រទេសជាសមាជិក រួមមានអាស៊ានបូកអូស្ត្រាលី និងនូវែលសេឡង់ (ASEAN + Australia and New Zealand) ព្រមទាំងពិភាក្សា និងអនុម័តលើបច្ចុប្បន្នភាពការងាររបស់គម្រោងសិក្សានានា ដែលរៀបចំដោយក្រុមប្រឹក្សាយោបល់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ។ ជាមួយគ្នានេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានចូលរួមមហាសន្និបាតប្រចាំឆ្នាំ២០២៤ របស់ក្រុមប្រឹក្សាយោបល់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ ចាប់ពីថ្ងៃទី២១-២៤ ខែឧសភា ឆ្នាំ២០២៤ នៅទីក្រុងមែលប៊ន ប្រទេសអូស្ត្រាលី

ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការ និងពិភាក្សារួមគ្នាលើគំនិតផ្តួចផ្តើមនិងនវានុវត្តន៍ថ្មីៗ ដើម្បីស្វែងរកដំណោះស្រាយលើការគំរាមកំហែងក្នុងតំបន់។

ទន្ទឹមនេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានផ្តល់ធាតុចូលក្នុងគម្រោងសិក្សាផ្សេងៗ របស់ក្រុមប្រឹក្សាយោបល់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ ដូចជាការបោះឆ្នោតជ្រើសរើសឈ្មោះថ្នាល នៃការចែករំលែកព័ត៌មានថ្នាក់តំបន់របស់ក្រុមការងារ បង្កើនសមត្ថភាពនិងភាពជាដៃគូ និង កម្រងសំណួរនៃគម្រោងរៀបចំផែនទីអង្គការភេរវករតំបន់។




**មហាសន្និបាតប្រចាំឆ្នាំ២០២៤ របស់ក្រុមការងារប្រឹក្សាយោបល់ ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ ចាប់ពីថ្ងៃទី២១-២៤ ខែឧសភា ឆ្នាំ២០២៤ នៅទីក្រុងម៉ែលប៊ន ប្រទេសអូស្ត្រាលី**

### ឃ. កិច្ចសហប្រតិបត្តិការទ្វេភាគី

បន្ថែមលើកិច្ចសហប្រតិបត្តិការខាងលើ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានសហការ រៀបចំកម្មវិធីវប្បធម៌ជាមួយមជ្ឈមណ្ឌលវិភាគនិងរាយការណ៍ប្រតិបត្តិការអូស្ត្រាលី ដែលជា អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុអូស្ត្រាលី (Australian Transaction Reports and Analysis Centre – AUSTRAC) នៅរាជធានីភ្នំពេញ ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយបណ្តាប្រទេស ក្នុងតំបន់។ ទន្ទឹមនេះ តាមរយៈការចុះអនុស្សរណៈយោគយល់ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និង AUSTRAC បានចូលរួមយ៉ាងសកម្មលើការបណ្តុះបណ្តាល និងការចែករំលែកបទពិសោធផ្សេងៗ។

ក្រៅពីនេះ កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានជួបពិភាក្សាការងារជាមួយនគរបាលសហព័ន្ធអូស្ត្រាលីប្រចាំកម្ពុជា ហៅកាត់ថា AFP ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នទាំងពីរ ពិសេសកិច្ចការអភិវឌ្ឍសមត្ថភាព ធនធានមនុស្សលើការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។





**កិច្ចពិភាក្សារវាងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**
**ជាមួយនគរបាលសហព័ន្ធអូស្ត្រាលី ប្រចាំកម្ពុជា**
**នាថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤ នៅអគារអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**

## ២.៩. ការពង្រឹងសមត្ថភាពធនធានមនុស្ស

*អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានបន្តពង្រឹងសមត្ថភាពមន្ត្រីបុគ្គលិកជាប្រចាំ លើការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។ ក្នុងឆមាសទី១ ឆ្នាំ២០២៤ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានរៀបចំវគ្គបណ្តុះបណ្តាលផ្ទៃក្នុងចំនួន ២ លើក អំពីបទដ្ឋានអន្តរជាតិ និងច្បាប់និងបទប្បញ្ញត្តិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មជូនមន្ត្រី-បុគ្គលិកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដែលមានមន្ត្រី-បុគ្គលិកចូលរួមសរុបចំនួន ៤៨ រូប។ ទន្ទឹមនេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ក៏បានរៀបចំវគ្គបណ្តុះបណ្តាលអំពីតួនាទី-ភារកិច្ចរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងនីតិវិធីសកលនៃការវាយតម្លៃអញ្ញមញ្ញរបស់ក្រុមការងារហិរញ្ញវត្ថុ ចំនួន ១ លើក ជូនមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា ដោយមានសិក្ខាកាមចូលរួមចំនួន ៤០ រូប។*






**វគ្គបណ្តុះបណ្តាល ស្តីពីបទដ្ឋានអន្តរជាតិ និងច្បាប់និងបទប្បញ្ញត្តិប្រឆាំងការសម្អាតប្រាក់**
**និងហិរញ្ញប្បទានភេរវកម្ម ដល់មន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា**
**នាថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤ នៅមណ្ឌលសិក្សាបច្ចេកទេសធនាគារ**

*អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានចាត់មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស ដែលរៀបចំដោយក្រសួង-ស្ថាប័នជាតិ និងអន្តរជាតិចំនួន ១៩ លើក ដោយមានមន្ត្រីចូលរួមសរុបចំនួន ៥៩ រូប។ ការចូលរួមវគ្គបណ្តុះបណ្តាលក្នុងប្រទេសមានចំនួន ៥ លើក ដែលរួមមានប្រធានបទ ១/- ការវាយតម្លៃហានិភ័យថ្នាក់ជាតិប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយ*

អាវុធមហាប្រល័យ ២/- ការវិភាគព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុក្នុងតំបន់ទន្លេមេគង្គ ៣/- ការស៊ើបអង្កេតបទល្មើសហិរញ្ញវត្ថុ ៤/- សន្តិសុខសាយប័រ និង ៥/- អត្ថប្រយោជន៍នៃការចូលជាសមាជិកសាមញ្ញនៃអង្គការគណៈកម្មការមូលបត្រអន្តរជាតិ។ ចំពោះវគ្គបណ្តុះបណ្តាលក្រៅប្រទេសមានចំនួន ១០ លើក ដែលរួមមានប្រធានបទ ១/- ការបណ្តុះបណ្តាលអ្នកវាយតម្លៃរបស់ក្រុមការងារហិរញ្ញវត្ថុ និងក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ ២/- ស្តង់ដាររបស់ក្រុមការងារហិរញ្ញវត្ថុពាក់ព័ន្ធនឹងការត្រួតពិនិត្យ ៣/- សេចក្តីណែនាំក្នុងការប្រើប្រាស់មុខងារអ៊ីម៉ែលក្នុងប្រព័ន្ធអ៊ិកម៉ុង ៤/- ការស៊ើបអង្កេត និងការចោទប្រកាន់ការសម្អាតប្រាក់ឆ្លងដែន និងអន្តរជាតិ ៥/- ការគ្រប់គ្រងសន្តិសុខ និងយុទ្ធសាស្ត្រពាណិជ្ជកម្ម ៦/- អំពើពុករលួយទ្រង់ទ្រាយធំ ៧/- ការប្រយុទ្ធប្រឆាំងការសម្អាតប្រាក់ដែលបានមកពីផលនៃបទល្មើសជួញដូរសត្វព្រៃខុសច្បាប់ ៨/- ហានិភ័យនៃហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ៩/- ការចងក្រងសំណុំរឿងបទល្មើសធំៗ និង ១០/- ទ្រព្យសកម្មនិម្មិត និងអ្នកផ្តល់សេវាទ្រព្យសកម្មនិម្មិត។




**វគ្គបណ្តុះបណ្តាលរួមគ្នារបស់ក្រុមការងារហិរញ្ញវត្ថុ និងក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក ស្តីពីការសម្អាតប្រាក់ ស្តីពីអ្នកវាយតម្លៃអញ្ញមញ្ញ**
**ចាប់ពីថ្ងៃទី៤ ដល់ថ្ងៃទី៨ ខែមីនា ឆ្នាំ២០២៤ នៅទីក្រុងហុងកុង ប្រទេសចិន**

ទន្ទឹមនេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយដូចខាងក្រោម៖

- សិក្ខាសាលាស្តីពីការផ្តល់មតិត្រលប់ពាក់ព័ន្ធនឹងការរាយការណ៍ប្រតិបត្តិការសង្ស័យ (STR Feedback Workshops) ចំនួន ២ លើក ជូនបុគ្គលរាយការណ៍ ជាគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ កាស៊ីណូ ក្រុមហ៊ុនអចលនទ្រព្យ និងក្រុមហ៊ុនធានារ៉ាប់រង ដោយមានមន្ត្រីប្រតិបត្តិចូលរួមសរុបចំនួន ៤៨៣ រូប ។
- សិក្ខាសាលាផ្សព្វផ្សាយសម្រាប់និយ័តករ និងបុគ្គលរាយការណ៍អំពីកាតព្វកិច្ចដែលមានចែងក្នុងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ចំនួន៦លើកមកពីគ្រប់វិស័យរួមមានធនាគារមីក្រូហិរញ្ញវត្ថុ ភតិសន្យា ទូទាត់សងប្រាក់

ត្បូងថ្មនិងលោហៈជាតុមានតម្លៃ កាស៊ីណូ អចលនវត្ថុ មូលបត្រ ធានារ៉ាប់រង សន្តិសុខសង្គម និងបរធនបាលកិច្ច ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ៤៤១ រូប និង

- សិក្ខាសាលាផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹង អំពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ជូនដល់សាស្ត្រាចារ្យ និងនិស្សិតសាកលវិទ្យាល័យជាតិគ្រប់គ្រង ដែលមានសិក្ខាកាមចូលរួមចំនួន ២៥០ រូប។



**សិក្ខាសាលាផ្សព្វផ្សាយសម្រាប់និយ័តករ និងបុគ្គលរាយការណ៍ ចំនួន ៦ លើក**
**ចាប់ពីថ្ងៃទី២៨-៣០ ខែឧសភា ឆ្នាំ២០២៤**
**នៅធនាគារជាតិនៃកម្ពុជា អគារសែនសុខ**

ក្រៅពីនេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានចូលរួមជាវាគ្មិនក្នុងសិក្ខាសាលាដែលសហការរៀបចំដោយអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និយ័តករមូលបត្រកម្ពុជា និយ័តករធានារ៉ាប់រងកម្ពុជា និងគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា សរុបចំនួន ១២ លើក ដោយមានសិក្ខាកាមចូលរួមសរុបចំនួន ៦២០ រូប។ សិក្ខាសាលាទាំងនេះផ្តោតលើប្រធានបទ ដូចជា ៖ ១/- បទដ្ឋានអន្តរជាតិរបស់ក្រុមការងារហិរញ្ញវត្ថុលើការវាយតម្លៃហានិភ័យ និងការកំណត់បទល្មើសនៃការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងវិធានការទប់ស្កាត់ដែលត្រូវអនុវត្តដោយបុគ្គលរាយការណ៍ ២/- ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម សេចក្តីណែនាំស្តីពីវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន និងសេចក្តីណែនាំស្តីពីការត្រួតពិនិត្យផ្ទៃក្នុងសម្រាប់បុគ្គលរាយការណ៍ និង ៣/- យន្តការរាយការណ៍ប្រតិបត្តិការ និងសេចក្តីណែនាំ ស្តីពីការបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យរបស់បុគ្គលរាយការណ៍ ស្ថិតក្រោមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

# ជំពូកទី៣

## ទិសដៅការងារឆមាសទី២ ឆ្នាំ២០២៤

សម្រាប់ឆមាសទី២ ឆ្នាំ២០២៤ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាមានទិសដៅដូចខាងក្រោម៖

- បន្តរៀបចំ និងសម្របសម្រួលការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម លើកទី២
- បន្តអនុវត្តការចុះត្រួតពិនិត្យដល់ទីកន្លែង ចំពោះបុគ្គលរាយការណ៍ ដែលស្ថិតក្នុងវិស័យធនាគារ មូលបត្រ ជានាវ៉ាប់រង អចលនវត្ថុ និងកាស៊ីណូ និងបន្តតាមដានការអនុវត្តតាមអនុសាសន៍ដែលបានផ្តល់ជូនបុគ្គលរាយការណ៍
- សហការជាមួយនាយកដ្ឋានព័ត៌មានវិទ្យាក្នុងការអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីសម្រួលដល់ការងារវិភាគ
- បន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ តាមរយៈការចុះអនុស្សរណៈយោគយល់ជាមួយនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ និងគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា
- បន្តពង្រឹងសមត្ថភាព និងចែករំលែកបទពិសោធដល់មន្ត្រីអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាទាក់ទងនឹងការអនុវត្តការងារជាក់ស្តែងលើការត្រួតពិនិត្យ និងវិភាគប្រតិបត្តិការហិរញ្ញវត្ថុ និង
- សហការជាមួយក្រសួង-ស្ថាប័នក្នុងស្រុក និងដៃគូអន្តរជាតិ ដើម្បីរៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា ក្នុងគោលដៅបន្តពង្រឹងចំណេះដឹងដល់បុគ្គលរាយការណ៍ និងភាគីពាក់ព័ន្ធ។

# អក្សរកាត់

| | | |
|---|---|---|
| គ.ស.ហ. | គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ | National Coordination Committee on Anti-Money Laundering and Financing of Terrorism and Financing of Proliferation of Weapons of Mass Destruction (NCC) |
| ក.ប.ស.ហ. | ក្រុមការងារបច្ចេកទេសអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម | The Technical Inter-Ministries Working Group on Anti-Money Laundering and Combating the Financing of Terrorism |
| ស.ហ.ក. | អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | Cambodia Financial Intelligence Unit (CAFIU) |
| អ.វ.ហ. | អនុគណៈកម្មាធិការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ | The Sub-Committee of National Risk Assessment on Money Laundering and Financing of Terrorism and Financing of Proliferation of Weapons of Mass Destruction |

| | | |
|---|---|---|
| AML/CFT/CPF | Anti-Money Laundering and Combating the Financing of Terrorism and Combating the Financing of Proliferation of Weapons of Mass Destruction | ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ |
| APG | Asia/Pacific Group on Money Laundering | ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ |
| AUSTRAC | Australian Transaction Reports and Analysis Centre | មជ្ឈមណ្ឌលវិភាគនិងរាយការណ៍ប្រតិបត្តិការនៃប្រទេសអូស្ត្រាលី |
| FATF | Financial Action Task Force | ក្រុមការងារហិរញ្ញវត្ថុ |
| FICG | Financial Intelligence Consultative Group | ក្រុមការងារប្រឹក្សាយោបល់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ |
| FUR | Follow-Up Report | របាយការណ៍វឌ្ឍនភាព |
| RBS | Risk Based Supervision | វិធីសាស្ត្រត្រួតពិនិត្យផ្អែកលើហានិភ័យ |
| WB | World Bank | ធនាគារពិភពលោក |

រៀបចំបោះពុម្ពដោយ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
Published by Cambodia Financial Intelligence Unit